# ការបោះបង្គោលស្លាកសញ្ញាសម្គាល់តំបន់គ្រប់គ្រងកសិជីវៈចម្រុះខេត្តសៀមរាប

តាមប្រពៃណី ប្រជាពលរដ្ឋប្រមាណ៨០ភាគរយនៃស្រុកជីក្រែង ខេត្តសៀមរាបជាកសិករធ្វើស្រែចម្ការនិងប្រកបរបរចិញ្ចឹមសត្វពាហនៈ នេសាទ បោចស្លឹករកឃ្មុំ និងកាប់អុស នៅក្នុងតំបន់វាលស្មៅលិចទឹកបឹងទន្លេសាប ។ ប៉ុន្តែរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ តំបន់វាលស្មៅលិចទឹកបឹងទន្លេសាបត្រូវបានបាត់បង់មួយភាគធំដោយសារសកម្មភាពជាច្រើនដូចជាការដៅព្រំចាប់យកដីជាកម្មសិទ្ធិ ការធ្វើអាងស្តុកទឹកសម្រាប់ធ្វើស្រែប្រាំងនិងការចាប់យកដីទុកក្នុងគោលបំណងផ្សេងៗដោយអ្នកមាន-អំណាច និងអ្នកមានសម្បត្តិស្តុកស្តម្ភ ។ បញ្ហានេះបានធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់ព្រៃលិចទឹក តំបន់ជម្រកត្រីជីវៈចម្រុះប្រព័ន្ធអេកូឡូស៊ីធម្មជាតិ និងទីជម្រកសត្វស្លាបសំខាន់ៗដូចជាសត្វឡិបជាដើម ។ ជាមួយគ្នានេះដែរអាជ្ញាធរខេត្តសៀមរាបសហការជាមួយអង្គការសត្វស្លាបអន្តរជាតិ ( Birdlife International) និងអង្គការសមាគមអភិរក្សសត្វព្រៃ (WCS) បានផ្តួចផ្តើមនូវកិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់ក្នុងការចាត់វិធានការនានា ដើម្បីទប់ស្កាត់បញ្ហានេះនិងដើម្បីការពារធនធានធម្មជាតិ រួមចំណែកដល់ការការពារនិងលើកស្ទួយជីវភាពប្រជា-ពលរដ្ឋដែលភាគច្រើនពឹងផ្អែកទៅលើតំបន់វាលស្មៅបឹងទន្លេសាបជាចម្បង ។

កាលពីថ្ងៃទី៣០ ខែឧសភាឆ្នាំ២០០៧ គណៈកម្មការដឹកនាំគ្រប់គ្រងតំបន់កសិ- ជីវៈចម្រុះខេត្តសៀមរាបបានបើកការប្រជុំពិភាក្សាជាថ្មីម្តងទៀតនៅសាលាស្រុកជីក្រែង ខេត្តសៀមរាប ក្រោមអធិបតីភាពលោកចាន់ សុផល អភិបាលរងខេត្តសៀមរាប និងជាអនុប្រធានគណៈកម្មការដឹកនាំគ្រប់គ្រងតំបន់កសិ- ជីវៈចម្រុះ ព្រមទាំងលោកប្រធានមន្ទីរនៅក្នុងខេត្តនិង-ស្ថាប័នដែលពាក់ព័ន្ធទាំងអស់ក្នុងគោលបំណងពិភាក្សាអំពីការបោះបង្គោលនៅតាមព្រំប្រទល់តំបន់គ្រប់គ្រងកសិ- ជីវៈចម្រុះស្រុកជីក្រែង ដើម្បីឱ្យប្រជាពលរដ្ឋសហគមន៍មូលដ្ឋាននិងស្ថាប័នពាក់ព័ន្ធទាំងអស់ស្គាល់កាន់តែច្បាស់នៃដែនកំណត់តំបន់គ្រប់គ្រងកសិ- ជីវៈចម្រុះនិងទប់ស្កាត់ការបំពានរានយកដីធ្លីពីបណ្តាបុគ្គលមួយចំនួន ។ ការប្រជុំពិភាក្សានេះបានសង្កត់ធ្ងន់ទៅលើការទន្ទ្រានដីធ្លីដោយអ្នកមានអំណាចនិងអ្នកមានលុយមួយចំនួនដែលបានរំលោភទន្ទ្រានចូលក្នុងតំបន់គ្រប់គ្រងកសិ- ជីវៈចម្រុះ-ប្រមាណជាង៥០០ហិកតានៃតំបន់ការពារទាំងអស់ដែលមានផ្ទៃដីចំនួនសរុប៤៦៣៦ហិកតា ។ នៅក្នុងកិច្ចប្រជុំនោះ លោកចាន់ សុផលបានផ្តល់នូវអនុសាសន៍និងជំរុញឱ្យស្ថាប័នពាក់ព័ន្ធទាំងអស់ជាពិសេសគឺលោកមេឃុំស្ពានត្នោត និងមេឃុំល្វែងឫស្សីដែលជាអាជ្ញាធរដែនដីនិងជាអ្នករស់នៅជុំវិញនិងក្នុងតំបន់គ្រប់គ្រងកសិ- ជីវៈចម្រុះសូមជួយផ្សព្វផ្សាយបន្ថែមអំពីតំបន់គ្រប់គ្រងកសិ- ជីវៈចម្រុះដែលបង្កើតឡើងក្នុងគោលបំណងការពារជីវៈចម្រុះនៅក្នុងតំបន់បឹងទន្លេសាបនិងដើម្បីរក្សានូវទំនៀមទម្លាប់ប្រពៃណីក្នុងការប្រកបមុខរបរចិញ្ចឹមជីវិតដូចជាការទាញផលពីធនធានធម្មជាតិតាមរយៈការនេសាទ ធ្វើស្រែ ប្រមូលរុក្ខជាតិទឹកសម្រាប់ជាបន្លែបង្ការ និងដើម្បីការពារនូវផ្លូវធ្វើដំណើរចូលប្រកបរបរចិញ្ចឹមជីវិតជាលក្ខណៈគ្រួសាររបស់ប្រជាពលរដ្ឋនិងតំបន់វាលស្មៅសម្រាប់ការចិញ្ចឹមសត្វពាហនៈជាដើម ។

ដូចគ្នានោះដែរ លោកចាន់ សុផល បានបញ្ជាក់យ៉ាងច្បាស់ថា មិនអនុញ្ញាតឱ្យមានការលក់-ផ្ទេរដីនៅក្នុងតំបន់គ្រប់គ្រងកសិ- ជីវៈចម្រុះឡើយ ព្រោះថាវាអាចនឹងបង្កឱ្យមានភាពអនាធិបតេយ្យដល់សង្គម ។ ជាលទ្ធផលបន្ទាប់ពីកិច្ចប្រជុំនោះសមាជិកទាំងអស់នៃអង្គប្រជុំទាំងមូលបានធ្វើដំណើរទៅដល់ទីតាំងនៃតំបន់គ្រប់គ្រងកសិ- ជីវៈចម្រុះដើម្បីបោះបង្គោលស្លាកសញ្ញាចំនួនប្រាំបីបង្គោលនៅតាមផ្លូវចូលនៃតំបន់គ្រប់គ្រងកសិ- ជីវៈចម្រុះដែលមានមនុស្សឆ្លងកាត់ ច្រើនដើម្បីជាសញ្ញាប្រាប់ដល់ប្រជាពលរដ្ឋទូទៅអំពីទីតាំងនៃតំបន់គ្រប់គ្រងកសិ- ជីវៈចម្រុះនេះ ។



*ស្លាកសញ្ញាសំគាល់ទីតាំងតំបន់គ្រប់គ្រងកសិ-ជីវៈចម្រុះ ខេត្តសៀមរាប*

ដកស្រង់ចេញពី រស្មីកម្ពុជា ឆ្នាំទី ១៥ លេខ៤៣០៥ ថ្ងៃសុក្រ ទី០៨ ខែមិថុនា ឆ្នាំ២០០៧